ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខ្សែ ៧

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណើម៉ង់
គ្រិ. ឆ្នាំ ១៩៣០
ពុ.ស ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ

១- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យ
កម្ពុជា ប្រែពីបាលីមកភាសាខ្មែរ (ត) . . . .
២- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត)
"មិលិន្ទបញ្ហា និង គតិលោកនេះ មិនបានចុះក្នុងនេះទេ ព្រោះមាន
បោះសៀវភៅដោយឡែកហើយ" . . . . .
៣- ប្រវត្តិរបស់វត្តពោធិភាល (បាត់ដំបង) អាចារ្យ អ៊ីវ-ឌូត ចៅអធិការវត្តនេះ
រៀបរៀង (ត) . . . . . . . . . ១៨៣
៤- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅ
ព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . ១៩៩

# ប្រវត្តិរបស់វត្តពោធិវាល

ឃុំវត្តសង្កែ ខេត្តបាត់ដំបង

ចៅអធិការ **អ៊ឹម-ឡូត** រៀបរៀង

(២)

---

ឯលោកគ្រូព្រះឧបជ្ឈាយ៍ ចន្ទ បានអាយុ៧៦ឆ្នាំ លោកក៏ទទួលអនិច្ចធម្មទៅ គ្រានោះមានលោកគ្រូសូត្រ ញ៉ាញ ជាចាស់ លោកមហាឈីន មកពីស្រុកសៀមវិញ លោកគ្រូសូត្រ ញ៉ាញ សឹក្ខ បានលោកមហាឈីន ជាមេវត្ត លោកមហា ឈីន ក៏តាំងរក្សាព្រះត្រៃបិដកហើយបង្រៀនភិក្ខុ-សាមណេរតមកមានភិក្ខុ ២ អង្គ ឈ្មោះភិក្ខុ គូរ ភិក្ខុ អន បានរៀនព្រះត្រៃបិដកក្នុងសំណាក់លោកអាចារ្យ ដោក លោកអាចារ្យ ចន្ទ ដល់អតីតលោកអាចារ្យទាំងពីរទៅភិក្ខុគូរ ភិក្ខុ អន ក៏រៀនក្នុងសំណាក់មហាឈីន ក មកឯលោកគ្រូសូត្រ ញ៉ាញ សឹក្ខទៅមិនយូរប៉ុន្មានចូលមកបួសក្នុងវត្តពោធិ-វាលវិញ ដល់ឯក្រោយលោកមហា ឈីន ជាមេវត្តលាសិក្ខាបទទៅ បានលោកគ្រូសូត្រ សំ ជាចៅអធិការ[1] លោកភិក្ខុបាម្ភៃក្រង់ខ្វាតខ្វាយព្រះត្រៃបិដក ទើបនិមន្តលោកអាចារ្យ អ៊ុន ពីវត្តទកាមក លោកអាចារ្យ

---

១- ចៅអធិការមានត្រឹមលោកគ្រូ សំ ធ្វើមេវត្តយូរឆ្នាំ ទើបមានព្រះរាជបញ្ញត្តឲ្យតាំងចៅអធិការ តែពួកអ្នកស្រុក ក៏នៅតែធ្លាប់មាត់ហៅលោកសង្ឃរាជនេះដល់សព្វថ្ងៃនេះ ។

ម៉ុក ជាសិស្សក៏តាមមកផងលោកអាចារ្យ អ៊ុក មកគង់ក្នុងវត្តពោធិវាល បានឡើងទីជាព្រះធម្មឃោសា ដោយហេតុលោកចៅពញាគតាធរ ញ៉ុញ ចៅហ្វាយស្រុកបាត់ដំបងទី ៧ មានសេចក្តីរាប់អានលោកគ្រូធម្មឃោសា នេះណាស់ថា ត្បិតលោកចេះព្រះត្រៃបិដកច្រើនលើសអ្នកប្រាជ្ញ ក្នុងស្រុក បាត់ដំបង ហើយមានវស្សាចាស់ផង ទើបតាំងជាព្រះឧបជ្ឈាយ៍លោក គ្រូធម្មឃោសាក៏មានសេចក្តីព្យាយាម បង្ហាញព្រះត្រៃបិដកដល់ភិក្ខុសាម-ណេរ ហើយលោកតាំងប្រែគម្ពីរបាលីជាសម្រាយច្រើនគម្ពីរ មានគម្ពីរ មង្គលទីបនីជាដើម លោកគ្រូសូត្រ នូវ ជាអ្នកសរសេរចុះក្រាំង ទើប ឧបាសកឧបាសិកាពល់គ្នាឃោសនាប៉ូលចារដាក់ស្លឹករឹត សម្រាប់វត្តពោធិវាលតមក លោកចៅពញាគតាធរ ញ៉ុញ ក៏មានសទ្ធាបានបរិច្ចាគទ្រព្យ ក្នុងមួយខែ ១០០ ដំឡឹងប៉ៃទៀតលោកយាយ ម៉ា បម្រុងបង្ហាន់ភិក្ខុសាមណេរ ដែលរៀនព្រះត្រៃបិដក ។

លុះឯក្រោយលោកអាចារ្យ កូរ និមន្តមកពីស្រុកសៀមវិញ លោក ក៏តាំងព្យាយាមបង្ហាញព្រះត្រៃបិដក ដល់ភិក្ខុសាមណេរ ក្នុងវត្តនៃ សព្វថ្ងៃ លោកអាចារ្យ កូរ មកនៅវត្តពោធិវាលបានបីឆ្នាំ កើតរោគក្អក ឈាម លោកក៏ទទួលអនិច្ចធម្មទៅ ក្នុងឆ្នាំនោះលោកចៅពញាគតាធរ ញ៉ុញ អញ្ជើញទៅស្រុកសៀម លុះត្រឡប់មកវិញនិមន្តលោកអាចារ្យ អឱ មកផង ។

លោកអាចារ្យ អន បានមកនៅវត្តពោធិ៍លវិញ លោកក៏តាំងបង្ហាញព្រះត្រៃបិដកតែសព្វថ្ងៃ លោកព្យាយាមក្នុងការដែលបង្ហាញផង ឈឺឆ្អាលក្នុងការថែរក្សាវត្តផង ហើយលោកក៏បានចាត់ឲ្យលើកថ្នល់តាំងអំពីមុខវិហាររហូតដល់មាត់ស្ទឹង មានទាយកគេសទ្ធា រកគ្រឿងឈើបម្រុងនឹងធ្វើកុដិប្រគេន កំពុងតែត្រៀមការ លោកបណ្ដាលកើតរោគពុកសៀត ទទួលអនិច្ចធម្មទៅ លោកអង្គនេះតាំងចិត្តបម្រុងវត្ត ដោយការមាំមួន តែលោកមកនៅវត្តពោធិ៍លបានតែ ៣ ឆ្នាំប៉ុណ្ណោះ ។

លុះឯក្រោយលោកគ្រូព្រះធម្មឃោសា អាយុលោកបាន ៧២ ឆ្នាំ លោកលាសិក្ខាបទទៅ បានលោកអាចារ្យ សន ជាសិស្សបង្ហាញព្រះត្រៃបិដកតមក ដល់មកឆ្នាំជូត ពុទ្ធសករាជ ២៤៣១ មណ្ឌបតម្កល់ព្រះបិដកក៏ទ្រុឌទ្រោមទៅ ដឡ្វៅ ហ៊ាន ថៃ ខេស មានសទ្ធាចេញទ្រព្យសាងហោត្រៃ ព្រមទាំងទូដាក់ព្រះត្រៃបិដក ហើយធ្វើកំផែងតដ្ឋជុំវិញ ចាត់ធ្វើជាស្រេច លុះនៅថ្ងៃ ១៤ កើត ខែចេត្រ ឆ្នាំថោះត្រីស័ក ពុទ្ធសករាជ ២៤៣៣ ដឡ្វៅ ហ៊ាន ថៃ ខេស ព្រមទាំងឧបាសក ឧបាសិកាដង្ហែព្រះត្រៃបិដកទៅតម្កល់លើហោត្រៃថ្មី ហើយចាត់ការធ្វើមានធម៌ទេសនាសង្គាយនាជាស្រេច ទើបនិមន្តលោកគ្រូសូត្រ នូ ឲ្យគង់រក្សាព្រះត្រៃបិដក ។

ក្នុងគ្រានោះព្រះវិហារដែលលោកយាយ ម៉ា សាងក៏ចាស់គ្រាំគ្រា ទើបហ្វូងកិប៊ុន គុយ អ្នកម៉ែ ទុ មានសទ្ធាចង់សាងវិហារថ្មី តែអធ្យាស្រ័យគាត់មិនចង់សាងនឹងកន្លែងចាស់ថា ត្បិតដីតទៅវែងខាងកើតណាស់ ហើយគាត់សង្ស័យថាទីដីមិនល្អ ត្បិតវត្តមិនសូវចម្រើនម្ដងហាក់ដូចជានឹងចម្រើនឡើង បានតិចប្រែអាប់ទុនចុះវិញ មួយទៀតព្រះសង្ឃក៏នៅមិនសូវស្រួល ដោយសេចក្ដីបំណងរបស់គាត់មិនបានគិតធ្វើតែវិហារមួយ គិតសាងអាគមទាំងអស់ធ្វើទាំងកំផែងក្រៅ ហើយធ្វើកុដិជាតឹកថៃសម្រាប់ភិក្ខុសង្ឃគង់ បើសាងស្រេចវេលាណាគាត់នឹងចូលបួសក្នុងព្រះពុទ្ធសាសនា ត្បិតគាត់ជាអ្នកមានទ្រព្យច្រើន មានទាំងជ្រះថ្លាក្នុងចិត្តពេញកម្លាំង ទើបទៅរកចិនសែដែលចេះមើលទីដីឲ្យមកមើល ចិនសែមកពិនិត្យមើលឃើញកន្លែងព្រះវិហារសព្វថ្ងៃនេះថាដីល្អ តែទំនាយថា ៥០ ឆ្នាំទៅមុខទៀត ទើបវត្តនឹងបានចម្រើនរុងរឿងគ្រប់ប្រការជាយូរលង់ទៅ ហ្វូងកិប៊ុន គុយ ក៏មានសេចក្ដីត្រេកអរជឿពេញទី ដោយគាត់ជាជាតិចិន ទំលាប់ចិនគេជឿដីហុងស៊ុយនេះណាស់ ។

លុះឲ្យចិនសែមើលស្រេច ទើបគាត់ទៅពិគ្រោះ និងលោកគ្រូចៅអធិការ សំ លោកក៏ព្រមទាំងអស់ ទើបគាត់ចាត់ឲ្យគគ្រឹះថយមកខាងលិច តែមិនបានថយឆ្ងាយទេយកកំផែងក្រោយវិហារចាស់ជាខាងមុខវិហារថ្មី បែរទៀងឯជើងបន្តិច ទើបហ្វូងកិប៊ុនទិមន្តឲ្យលោកគ្រូ

សូត្រ នូវ ជាអ្នកជួយត្រួតការ ហើយគាត់ទៅនិមន្តលោកព្រះធម្មចរិយានុកូល គឺព្រះធម្មចរិយាព្រំធ ទី១ ជាព្រះរាជាគណៈធំវត្តសង្កែ ១ និមន្តលោកគ្រូបាឡាត់ ឈុន ជាព្រះឧបជ្ឈាយ៍វត្តកណ្ដាល ១ ទាំងពីរអង្គនេះ ជាអធិបតីមើលការខុសត្រូវប្លុកព្រះវិហារសមឬមិនសម ស្រេចនឹងលោកគ្រូទាំងពីរអង្គបង្គាប់លើជាងទាំងអស់ លុះបានគ្រឿងព្រះវិហារគ្រប់ប្រដាប់ក៏ប្រជុំគ្នាលើក នៅថ្ងៃ១០កើត ខែពិសាខ ឆ្នាំមមែសប្តស័ក ពុទ្ធសករាជ ២៤៣៨ ហើយហ្វូងកិប៊ិនបានប្រគេនដីជាប់ទីងព្រំរបងឯត្បូងវត្ត ទទឹង ៣០ ម៉ែត្រ បណ្ដោយ ១៩ ម៉ែត្រ តាអ៊ីន យាយ ម៉ម បានប្រគេនដីជាប់ទីងរបងខាងឯជើង ទទឹង ១៨ ម៉ែត្រ បណ្ដោយ ១៨ ម៉ែត្រ ។

ឯវិហារលើកបានតែតួឡើង ហ្វូងកិប៊ិន គុយ ក៏ទទួលមរណភាពទៅ នៅតែលោកយាយ ឌុ ជាភរិយា ខាងមរតកហ្វូងកិប៊ិនក៏កើតក្ដីរ៉ាំង ដណ្ដើមគ្នា អ្នកយាយ ឌុ ក៏ឈប់ធ្វើវិហារនោះទៅ ។

ឯលោកគ្រូចៅអធិការឃើញថា អ្នក ឌុ ឈប់ធ្វើវិហារហើយ លោកឲ្យជស្ដៅ ហាន ថៃ ទេស និងអ្នក សាប់ មកពិគ្រោះថា តពីហ្វូងកិប៊ុលទៅ សីមាមិនទាន់បានបញ្ចុះ ឲ្យអ្នកទាំងពីរជួយគិត ជស្ដៅ ហាន និង អ្នក ជា ក៏មានសទ្ធាទទួលចេញទ្រព្យស្មើគ្នា ទើបសូមច្បាប់អនុញ្ញាតដល់រាជការ ។ ក៏អនុញ្ញាតច្បាប់ឲ្យអ្នកទាំងពីរ ក៏ខំខ្វល់ខ្វាយរកគ្រឿង

ប្រជាប់បាន ទើបអញ្ជើញទៅពញាគធាធរ ឈុម មកជាអធិបតី ហើយនិមន្តជុំនុំសង្ឃសូត្រ ដកសីមាចាស់នៅថ្ងៃ ៣ កើត ខែផល្គុណដល់ថ្ងៃ ៤ កើត ខែផល្គុណ ឆ្នាំរកានព្វស័ក ពុទ្ធសករាជ ២៤៤០ ក៏បញ្ចុះសី-មាថ្មីជាសូរេច ជនៅ ហ៊ាន និងអ្នក សាប់ ធ្វើបុណ្យបញ្ចុះសីមាក្នុងគ្រានោះអស់ប្រាក់ប្រាំពីររយរៀល លុះដល់មកឆ្នាំ ប លោកអាចារ្យ សន បានទទួលជាព្រះវិន័យធរ លោកគ្រូសូត្រ នូ និងព្រះវិន័យធរ សន ក៏ខំឃោសនាឧបាសក ឧបាសិកា ជញ្ជូនដីចាក់គ្រឹះកន្លែងព្រះវិហារលុះពេញ ។

ព្រះវិន័យធរ សន និងលោកគ្រូសូត្រ នូ ទាំង ២ អង្គនេះ មានសេចក្តីឈឺឆ្អាលនឹងវត្តអារាម ហើយតាំងព្រះទ័យទំនុកបម្រុងព្រះពុទ្ធសាសនាស៊ើគ្នា ព្រះវិន័យធរ សន ពិគ្រោះនឹងលោកគ្រូសូត្រ នូ ថា វត្តពោធិ៍វាលនេះ លោកអំពីដើម លោកមិនទទួលមានប្រាក់កាក់ទុកដាក់ប្រើប្រាស់ ដោយដៃឯង ផ្លូវប្រតិបត្តិនោះទើបតែនឹងប្រែត្រឹមលោកអាចារ្យ ជោក មក យើងគួរតែតាំងប្រព្រឹត្តឡើងវិញ ព្រះវិន័យធរ សន ទើបតែនឹងផ្តើមគិត ក៏ដាស់ចិត្តដល់ពួកភិក្ខុនិងឧបាសកកើតសេចក្តីផ្តើលឡើងលោកគ្រូតាំងពីព្រះអង្គ លុះអំណាចភយាគតិ ក៏ខានមិនបានប្រែត្ត ។

លុះដល់មកឆ្នាំ កុរឯកស័ក ព្រះវិន័យធរ សន បានបាត់សាងសាលា ១ សម្រាប់ឧបាសក-ឧបាសិការក្សាឧបោសថ ដល់ឆ្នាំជូតលោកចៅពញា គតាធរ ឈុម និមន្តព្រះវិន័យធរ សន ទៅធ្វើជាចៅអធិការវត្តកំផែងព្រះ វិន័យធរសន បានទទួលទីជាព្រះធម្មានុសិទ្ធិហាទឯលោកគ្រូ ញុំញុំគេនិមន្ត ទៅធ្វើចៅអធិការវត្តពោធិ ក្នុងវត្តពោធិវាល បានលោកអាចារ្យ កិន អាចារ្យ ឡាច បង្ហាញព្រះត្រៃបិដក ឯកិច្ចការក្នុងអារាមបាន លោកគ្រូសូត្រ នូវ យកចិត្តឈើផ្អាលថែទាំ បានសេចក្តីចម្រើនទាំងវត្តទាំងវិជ្ជារៀន ហើយ លោកសាងគម្ពីរប្រែរាយជាច្រើនគម្ពីរ បំណែកខាងធម៌វិន័យលោកក៏ខំ សិក្សា ហើយខំគោរពប្រតិបត្តិតាមធម៌វិន័យ លោកមានព្រះទ័យឈើផ្អាល ដល់ព្រះពុទ្ធសាសនាដោយការមាំមួន ពួកអ្នកស្រុកមានសេចក្តីពេញចិត្ត យកកូនមកប្រគេនជាសិស្សឲ្យរៀនក្នុងសំណាក់ ជាច្រើន ទាំងលោក ចៅហ្វាយស្រុកបាត់ដំបង ក៏មានសេចក្តីរាប់អានលោកគ្រូសូត្រ នូវ នេះ ណាស់ ក្នុងគ្រានោះវត្តពោធិវាលបានសេចក្តីរុងរឿងឡើង ។

ខ្ញុំជាអ្នករៀបរៀងសាវតារ ក៏មានសេចក្តីពេញចិត្តនឹងលោកគ្រូសូត្រ នូវ ជាយ៉ាងក្រៃពេក តែកម្មស្តាយព្រោះលោកកំពុងតែខំរៀបវត្ត ទាំង ធម៌វិន័យកំពុងតែបាតឲ្យសិស្សខំរៀន លោកគិតការមិនទាន់សម្រេចមក មានវិបត្តិកើតរោគម្រិញ គ្រូធ្វើថ្នាំប្រគេនពាន់ជាច្រើនមុខមិនប្រកប រោគ បេះតែចម្រើនខ្លាំងឡើងលោកក៏ទទួលអនិច្ចធម្ម នៅថ្ងៃ ៤ កើត ខែ

បុស្ស ឆ្នាំឆ្លូវ ទោស័ក ពុទ្ធសករាជ ២៤៨៣ អាយុលោកបាន ៨៦ ឆ្នាំ សិស្សទាំងអស់បានចាត់ធ្វើបុណ្យរំលាយសពស្រេច ពួកញាតិលោក យកអដ្ឋិទៅធ្វើឯវត្តកុល ព្រោះភូមិកំណើតលោកនៅភូមិកន្ទួត ក្រោមវត្តកុល សាច់ញាតិលោកនៅទីងព្រែកកុលជាច្រើន តែកាលលោកពីក្មេងញោមលោកយកមកផ្ញើឲ្យនៅរៀនទីងលោកអាចារ្យ ជោក វត្តពោធិវាល ។

លុះលោកគ្រូសូត្រ នូវ ទទួលអនិច្ចធម្មទៅ ពួកឧបាសក-ឧបាសិកា ព្រមទាំងជស្តៅ ហ៊ិន ចៃ ទេស យល់ឃើញថាលើហោត្រៃនោះមានតែលោកតា ញិក ១ អង្គ ជាញាតិនិងលោកគ្រូសូត្រ នូវ ទើបជំនុំពិគ្រោះគ្នាថា ឥឡូវនេះកុដិលោកគ្រូចៅអធិការ សំ ក៏ចាស់គ្រាំគ្រា មួយទៀតហោត្រៃបើឲ្យលោកតា ញិក នៅ ១ អង្គឯង ក្រែងគ្រប់គ្រងមិនឈ្នះព្រះត្រៃបិដក ក៏នឹងបាត់ខ្ចាត់ខ្ចាយ ទើបព្រមគ្នាទៅនិមន្តលោកគ្រូចៅអធិការឡើងទៅគង់ ឯខាងលោកតា ញិក គិតថាហោត្រៃគេអំពីលោកគ្រូសូត្រ នូវ នឹងបានខ្លួនគ្រប់គ្រងសម្រេចការលើហោត្រៃ ដល់គេគិតនិមន្តលោកគ្រូចៅអធិការឡើងទៅគង់ ក៏ថ្នាក់ចិត្តថយតំរិះគិតមិនចង់នៅ ក្នុងវត្តពោធិវាល គិតថយទៅនៅភូមិកំណើត ឯចំការស្វាយក្រោមបាណន់ ខែត្របាត់ដំបង ដោយអំណាចអភិជ្ឈាគ្របសង្កត់មិនគិតការខុសត្រូវលបគិតរកទូកមួយបានតាំងជញ្ជូនយកគម្ពីរជាច្រើនគម្ពីរព្រមទាំងរបស់គរុភណ្ឌចុះទូកថយចេញអំពីវត្តពោធិវាលមុនអរុណរះ លុះព្រឹកឡើងលោកគ្រូចៅ

អធិការដឹងគំនិតភិក្ខុ ញិក គិតទុច្ចរិតដូចនោះ ក៏មិនហ៊ានបង្អង់ ទៅប្តឹងលោកព្រះធម្មសាមិសារពង្ស គឺព្រះធម្មចរិយាត្រិធទី ១ ជាព្រះរាជាគណៈធំវត្តសង្កែ ព្រះរាជាគណៈ ក៏ចាត់ឲ្យបម្រើទៅតាមទាន់ពាក់កណ្តាលផ្លូវនាំយកទូកទាំងភិក្ខុ ញិក មកជំនុំជំរះថា ត្រូវឲ្យយកគម្ពីរសម្រាប់វត្តពោធិរាលដូចដើម លោកភិក្ខុ ញិក អង្វរសូមខ្ចីគម្ពីរប្រែរយពាក់កណ្តាល យកទៅទុកមើល ហើយសន្យាថា ដល់ដកទឹងយកមកជូនវិញជាប្រាកដមិនខាន លោកគ្រូចៅអធិការនឹងព្រះរាជាគណៈក៏ព្រម ចំណែកគម្ពីរដែលយកមកប៉ុន្មានលោកគ្រូចៅអធិការ ក៏យកមកទុកឯវត្តពោធិរាលវិញ ។

ឯភិក្ខុញិកទៅធ្វើផ្ទះនៅចំការស្វាយ នៅមិនយូរប៉ុន្មានភ្លើងឆេះអស់ទៅទៀត តែគម្ពីរដែលភិក្ខុញិកយកទៅសុទ្ធតែគម្ពីរប្រែរយនិងក្បួនច្បាបផ្សេងៗ ។

ឯខាងវត្តពោធិរាលលោកអាចារ្យ ភិន អាចារ្យ ឡាច ក៏លាសិក្ខាបទសិក្ខទៅ ក្នុងគ្រានោះវត្តពោធិរាល ចន្លោះពុំមានអាចារ្យ លុះដល់មកឆ្នាំជោះឆស័ក ជន្ខៅ យក់ ថៃ យ៉ង់ គិតឃើញថាព្រះវិហារដែលហ្វង់ភិប៊ុន គុយ ធ្វើនោះមិនទាន់ស្រេច ពុំមានអ្នកឯណាសង្ខាធ្វើតទៅជន្ខៅ យក់ គិតឃើញដូចនេះ ក៏កើតសទ្ធាចង់កសាងឲ្យបានសម្រេចទើបជន្ខៅ យក់ បបួលជន្ខៅ រាទ ថៃ ធិម ១, ជន្ពៅ ប៊ី ថៃ ងិន ១, ជន្ខៅឆាយ ថៃ ស៊ួរ ១, អ្នកទាំង ៤ នាក់នេះចេញប្រាក់មួយពាន់រៀលម្នាក់

បួននាក់ជាប្រាក់បួនពាន់ ដង្ហៅ យក់ ចេញគ្រួតការខ្លួនឯង ចាត់ជួល ចិនជាងខ្មែរមកលាបដញ្ញាំង ធ្វើប៉ាំងសាច ធ្វើកំផែង ខ្លោងទ្វារ ធ្វើ ក្បាច់ស៊ុម ទ្វារបង្អួច តែមិនបានបិទមាស ឯហោជាងនិងជងក្តារជហ្វាជះ របស់ហ្វូង គិប៊ុន ដង្ហៅ យក់ បិទមាសប្រដាប់កញ្ចក់លើកដាក់ហើយព្រំ កំពោរធ្វេកាពគ្រប់ជ្រុង ឯវិហារនោះទទឹង ១៦ ម៉ែត្រ បណ្តោយ ២៦ ម៉ែត្រ កំផែងទទឹង ៣៤ ម៉ែត្រ ៥០ សង្ទីម៉ែត្រ បណ្តោយ ៤៨ ម៉ែត្រ៤៥ សង្ទី ម៉ែត្រ, ចិត្តដង្ហៅ យក់ គ្រានោះសទ្ធាគាត់មាំណាស់ តែមកគិត បារម្ភថាធ្វើល្អទៅគ្មានអ្នករក្សាថែទាំរបស់នោះ មិនបិតថេរទៅបាន គិតដូចនេះ គាត់ក៏ឈប់ធ្វើ ត្បិតវត្តពោធិវាលក្នុងគ្រានោះ អាប់ខុនចុះជា ដពប ព្រោះលោកព្រះគ្រូ សន ទៅនៅវត្តកំផែង សិស្សលោកក៏តាម ទៅផង អស់អំពីលោកគ្រូស្មូត្រ ទូវ លោកអាចារ្យ កិន អាចារ្យ ឡាប ទៅ សិស្សលោកប៉ុន្មានក៏បែកទៅវត្តដទៃ ឯលោកគ្រូចៅអធិការព្រះ ទំយលោកសន្តោសមិនធុរៈនឹងអ្វី យកសុខតែ ១ អង្គលោក ទោះកុដិ បាក់បែកទ្រុឌទ្រោមដូចម្តេចក្តី ក្នុងទីវត្តព្រៃដុះស្តុកពេញវត្តលោកក៏មិន ធុញ លោកគ្រូចៅអធិការនេះ លោកជាអាចារ្យប្រដៅកម្មដ្ឋានផង ។

លុះដល់ឆ្នាំមមែនឮស័ក ពុទ្ធសករាជ ២៤៤១ ស្រុកបាត់ដំបង ឡើងទៅក្រុងកម្ពុជាវិញ លោកព្រះគ្រូ សន ជាចៅអធិការវត្តកំផែង ជូន ដំណើរលោកចៅពញាគតាធរ ឈុម ទៅស្រុកសៀម វត្តកំផែងបាន

លោកគ្រូអាចារ្យ សោម ស្តីទីចៅអធិការ លោកព្រះគ្រូ សន ទៅនៅស្រុកសៀមបាន ១ វស្សា ត្រឡប់មកស្រុកបាត់ដំបងវិញ មកនៅរក្សាញោមឯវត្តពោធិវាល ត្បិតញោមក៏ជរា លោកមកគង់ក្នុងវត្តពោធិ-វាលបាន ១ វស្សា លុះដល់ចេញវស្សារាជការមានរង្កៀសចិត្ត បង្គាប់ឲ្យចូលទៅភ្នំពេញទៅគង់នៅវត្តឧណ្ណាលោមជាយូរខែ ។

សម្តេចព្រះសង្ឃរាជ ទ្រង់ពិនិត្យយល់ឃើញ លោកព្រះគ្រូ សន បរិសុទ្ធឥតទោស ទើបនាំសេចក្តីចូលថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិតលើត្បូង បានទ្រង់យល់តាមសេចក្តីពិត ក៏ទ្រង់ព្រះមេត្តាថាលោកព្រះគ្រូ សន កាលរាជការសៀមធ្លាប់ទទួលដំណែងទីជាព្រះគ្រូធម្មានុសិទ្ធសាទរ ទើបទ្រង់ប្រោសចេញព្រះរាជប្រកាសតាំងលោកព្រះគ្រូ សន ជាព្រះគ្រូកម្ពុជរតនវង្ស នៅថ្ងៃអង្គារ ១៦ កើត ខែកត្តិក ឆ្នាំរកាឯកស័ក ពុទ្ធសករាជ ២៤៥១ ត្រូវនឹងថ្ងៃ ២៣ ខែ ណូវែម ឆ្នាំ ១៩០៨ ហើយទ្រង់អនុញ្ញាតឲ្យលោកព្រះគ្រូ សន ចូលមកនៅវត្តពោធិវាល ស្រុកបាត់ដំបងដូចដើមវិញ ពួកឧបាសក-ឧបាសិកាឃើញថា លោកព្រះគ្រូ សន គ្មានកុដិនៅផង គ្មានទីនឹងបង្ហាញព្រះត្រៃបិដកផង ទើបឃោសនាគ្នាបានជាប្រាក់ប្រាំរយរៀលសាងកុដិ លុះធ្វើកុដិស្រេច លោកគ្រូចៅអធិការ សំ គិតឃើញថា ហោត្រៃដែលលោកនៅនោះគ្រាំគ្រា តាំងកាយលោកក៏កាន់តែជរា នឹងរក្សាព្រះត្រៃបិដកមិនបានអ្នកដែលខ្ចីគម្ពីរទៅ ខ្លះក៏យក

មកជូនវិញ ខ្លះក៏បំបាត់យកទុកជារបស់ទៅក៏មាន លោកឃើញហេតុដូច្នេះ ទើបលោកប្រគល់ព្រះត្រៃបិដក ព្រមទាំងទូឲ្យលោកព្រះគ្រូ សន យកមកទុកឯកុដិថ្មី ឯកិច្ចខាងព្រះអាពាសទៀត ក៏ប្រគល់ឲ្យលោកព្រះគ្រូ សន ទទួលជាភារៈលើខ្លួនទាំងអស់ ។

ឯលោកគ្រូចៅអធិការ សំ ព្រះធម្មចរិយាព្រឹទ្ធ ព្រះរាជគណៈធំវត្តសុភី តាំងឲ្យធ្វើជាព្រះឧបជ្ឈាយ៍ លោកព្រះគ្រូសន ក៏ទំនុកបម្រុងព្រះអាពាស ហើយបង្ហាញព្រះត្រៃបិដកតមកបណ្តាពួកឧបាសក-ឧបាសិកា បានលោកព្រះគ្រូ សន មកគង់វត្តពោធិពល ក៏មានសេចក្តីរាប់អានយកកូនមកទុកឲ្យនៅរៀនសូត្រ អ្នកដែលបែកទៅវត្តដទៃ ក៏ត្រឡប់មកធ្វើបុណ្យវត្តពោធិពលវិញខ្លះ ឯជផ្ញើ យក់ និងឧបាសិកា ធិម ក៏មានសេចក្តីពេញចិត្ត ព្រោះគាត់តាំងចិត្តនឹងទំនុកបម្រុងវត្តពោធិពលនេះជានិច្ច គាត់ឃើញវត្តដទៃសុទ្ធតែមានអ្នកមានទ្រព្យ គេទំនុកបម្រុងច្រើន ឯវត្តពោធិពលនេះ ឧបាសកជើងវត្តក៏តិចហើយសុទ្ធតែអ្នកខាត់ពាល់តាមសព្វរបស់គាត់ មានតែញទទទ្ធឹងចាំតែមានលោកគ្រប់គ្រងវត្តដោយការមាំមួន គាត់ទើងតាំងខ្លួនជាឧបដ្ឋាកទំនុកបម្រុងវត្តឲ្យបានរុងរឿង ។

លុះបានលោកព្រះគ្រូ សន មកគង់វត្តពោធិពលវិញ គាត់ក៏មានសេចក្តីត្រេកអរបេបួលរៃ ធិម ថាយើងទាំងពីរតាំងចិត្តទំនុកបម្រុងវត្តពោធិពលឲ្យបាន ឲ្យបានរុងរឿងឡើង បើកង់វត្តខ្លះខាតអ្វីទទួលសាង

ឲ្យមានគ្រប់ប្រដាប់ ដែលគាត់គិតសង់បានបបួលឧបាសិកា ជិម ឲ្យចេញទ្រព្យស្មើគ្នា គឺសាងគ្រែទេសនា ធ្វើជាបុស្បុក ៣ ថ្នាក់ មានដំបូល ហើយបិទមាសជាក្បាច់ ធ្វើស្រេចគិតជាប្រាក់អស់ ៥០០ រៀល គាត់ឃើញសាលាចាស់ដែលលោកព្រះគ្រូ សុខ ចាត់សាងនោះតូចចង្អៀត ព្រោះក្នុងវត្តមួយមានតែសាលាមួយ ទើបដង្កោ យក់ និងឧបាសិកា ជិម ចង់សាងថ្មី ១ ទៀត ទើបអ្នកទាំងពីរចេញប្រាក់ទិញឈើព្រមទាំងគ្រឿងប្រដាប់សាលា បានព្រមមកទុកក្នុងវត្តមិនទាន់បានចុះដៃធ្វើ ដង្កៅ យក់ ចាប់ជម្ងឺឈឺក៏ទទួលអនិច្ចកម្មទៅ ។

ដង្កៅ យក់ នេះកាលពីក្មេងគាត់នៅវត្តពោធិវាល ជាសិស្សលោកអាចារ្យ អន លុះអត់អំពីដង្កៅ យក់ ទៅ ឧបាសិកា ជិម និងដង្កៅ ធួង ជាកូនដង្កៅ យក់ ក៏ចាប់ធ្វើសាលានោះ លុះធ្វើស្រេចគិតជាប្រាក់អស់បីពាន់ពីររយរៀល ។

ឯលោកព្រះគ្រូ សុខ មកគង់ក្នុងវត្តពោធិវាល បាន ៥ ឆ្នាំ រោគក៏-កាន់តែចម្រើនឡើង លុះដល់មកថ្ងៃពុធ ១ កើត ខែអាសាឍ ឆ្នាំខាល លោកចូលទៅឧមស្សការព្រះក្នុងវិហារ គិតនឹងចូលវស្សា ក៏បណ្ដាលកើតរោគខ្យល់គ ផុតស្មារតីមិនដឹងខ្លួន គ្រូខ្មែរទាំងចិនសែ ប្ដូរពេទ្យបារាំងក៏រក្សារោគនោះមិនបាន ដល់មកថ្ងៃសៅរ៍ ៤ កើតខែអាសាឍ វេលារសៀលម៉ោង ៤ លោកក៏ទទួលអនិច្ចធម្មទៅ ភិក្ខុ ខួត ព្រមទាំងសិស្ស-

ទាំងអស់ ក៏ចាត់ចែងធ្វើបុណ្យឈាបនកិច្ចស្រេច ទើបលោកគ្រូចៅ-
អធិការព្រមទាំងព្រះរាជាគណៈ ក៏ប្រគល់គុដិព្រមទាំងព្រះត្រៃបិដកឲ្យ
លោកភិក្ខុ នួត គ្រប់គ្រង ហើយឲ្យធ្វើជាគ្រូសូត្រ កិច្ចធុរៈក្នុងអារាម
ប៉ុន្មាន ក៏ប្រគល់ឲ្យជាភារៈលើគ្រូសូត្រ នួត ទាំងអស់ គ្រូសូត្រ នួត
ក៏ទទួលធុរៈរក្សាព្រះត្រៃបិដក ហើយថែទាំវត្តអារាមរៀងមក ។

លុះឯក្រោយគ្រូសូត្រ នួត គិតឃើញថាអដ្ឋិលោកព្រះគ្រូ សុខ ក៏
មិនទាន់បញ្ចុះ ស្តូបរកអដ្ឋិលោកគ្រូសូត្រ នូវ លោកអាចារ្យ អុន ក៏មិន
ទាន់បញ្ចុះ ទើបគិតបបួលពួកឧបាសក-សិកាព្រមទាំងពួកសិស្សានុសិស្ស
កសាងជាព្រះចេតិយ៍មួយ ខាងទិសអគ្នេយ៍ក្នុងកំផែងព្រះវិហារ ព្រះ
ចេតិយ៍នោះទំហំជើងក្រោម ៣ ម៉ែត្រ ៣០ សង់ទីម៉ែត្រ ៤ ជ្រុង កំពស់ ៩
ម៉ែត្រ ខាងលើតម្កល់ព្រះពុទ្ធរូបដែលបែកបាក់ ខាងក្រោមបញ្ចុះអដ្ឋិ
លោកព្រះគ្រូគម្ពុជរតនរង្សី សុខ ១ លោកគ្រូអាចារ្យ អុន ១, លោកគ្រូ
សូត្រ នូវ ១, ព្រះចេតិយ៍ធ្វើស្រេចនូវថ្ងៃ ១០ កើត ខែកត្តិក ឆ្នាំខាល-
ឆស័ក ពុទ្ធសករាជ ២៤៧៦ ក្នុងឆ្នាំនោះ ដន្ទៅ ហ៊ិន ឧបាសិកា ឯម
ចេញទ្រព្យប្រាំបួនរៀល សាងព្រះពុទ្ធរូបប្រាក់អង្គឈរ ១ អង្គ ឯវត្ត
ពោធិពល ក្នុងគ្រានោះចន្លោះពុំមានអ្នកប្រាជ្ញ មានតែសាមណេរ សុជ
បានរៀនទីងលោកគ្រូគម្ពុជរតនរង្សី សុខ ដល់អត់អំពីលោកទៅវិជ្ជានូវ
ស្មើរដប់មកឆ្នាំរោះ គ្រូសូត្រ នួត ជូនទៅទុកឲ្យនៅរៀនឯស្រុកសៀម

គ្រូសូត្រ ខួត ក៏ត្រឡប់ចូលមកស្រុកបាត់ដំបងវិញ គិតនឹងធ្វើបល្ល័ង្កព្រះដ៏ធំ ទើបឲ្យឧបាសក ហ៊ុល ទៅនិយាយនឹងជាង តោ នៅភូមិដូនទាវ ជាបល្ល័ង្កនេះកាលរំកិលព្រះមកអំពីវិហារចាស់ ជាង តោ ក៏ប់ថានឹងធ្វើ ឥឡូវនេះយូរឆ្នាំហើយមិនទេះបានសម្រេច បើជាង តោ ទទួលធ្វើនឹង ក៏ប់ជួយពេញកម្លាំង ជាង តោ ក៏មានសេចក្ដីត្រេកអរថា គាត់ក៏គ្មានក្មេច តែចាស់និងគ្មានទ្រព្យនឹងធ្វើ បើលោកគ្រូសូត្រជួយគាត់នឹងក៏ប់ធ្វើ គ្រូសូត្រ ខួត បានដំណឹងដូចនោះ ក៏ទៅនិយាយនឹងឧបាសិកា ធិម ជាឧបដ្ឋាកវត្តឲ្យជួយចេញទ្រព្យឧបាសិកា ធិម ក៏មានសេចក្ដីពេញចិត្ត ទទួលក៏ប់ថា បើធ្វើអស់ប៉ុន្មានគាត់ទទួលចេញលុះតែសម្រេច គ្រូសូត្រ ខួត ក៏ចាត់ធ្វើជាង តោ ជាជាងប្រដាប់ក្បាច់ ឧបាសក ហ៊ុល ក៏ជួយខ្វល់ខ្វាយ ខ្វះខាតអ្វីក៏តែរកមកបំពេញ ចុះធ្វើពីខែកត្តិកឆ្នាំថោះមក ។

(នៅមានត)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

(ត)

---

## ភាគដប់

## ការតតញប្រសប់

ថ្ងៃតមកអំពីថ្ងៃដែលមានជ័យ មានការប្រជុំធំជាផ្លូវរាជការ ដើម្បីប្រកាសពិធីដ៏មានជ័យមុខគួរបីតិត្រេកអរឲ្យប្រាកដកិត្តិយសទូទៅថា កងទ័ពក្រុងរាជមានជ័យជម្នះកងទ័ពកុរុយ៉ាងស្រស់ មុខព្រះទីនាំងគំនាល់ពេញទៅដោយមនុស្ស ប្រៀតបៀតញៀតញ៉ាក់គ្នាស្ទើរដកដង្ហើមមិនរួច អ្នកដំណាងរាស្ត្រគ្រប់ពួកគ្រប់ជាន់បាននាំគ្នាមកគុះករ ដើម្បីមានចំណែកនៃសេចក្តីសោមនស្សរីករាយ វេលាមុនដែលព្រះចៅក្រុងនឹងស្តេចយាងចេញកាត់ទីប្រជុំ មានរឿងចម្លែកប្លែកអស្ចារ្យមុខគួរឆ្ងល់ គឺមានមនុស្សប្លែកមុខម្នាក់ឡើងទៅអង្គុយលើបល្ល័ង្កគង់ព្រះរាជាធិរាជ ប្អូននាក់ទៀតមុខមាត់ប្លែកដែរ តែងកាយយ៉ាងក្សត្រិយ៍ ឈរសម្តែងកិរិយាគោរពប្តូគាល់ជុំវិញបល្ល័ង្កនោះ នេះជាឧប្បត្តិហេតុដ៏កំបាំងធ្វើឲ្យទីប្រជុំមានសេចក្តីងឿងឆ្ងល់ជាបំផុត តែគ្មាននរិករាស្ត្រណាមួយហ៊ានហើបមាត់បរិហារថាម្តេច បានតែខ្សឹបខ្សៀវគ្នាតិចៗ និងសំឡឹងមើល ហើយមើលទៀត ដោយ

សង្ស័យ អ្នកប្លែកមុខនេះជាអ្នកណាហ្ន៎ តែគង់ជាមិនមែនអ្នកក្បត់ដណ្ដើមរាជសម្បត្តិ អ្នកខ្លះនឹកឃើញស្រពិចស្រពិល មើលទៅប្រហែល ៗ ជានឹងចាំមុខអ្នកប្លែកមុខអម្បាលនេះបានពីរបីនាក់ តែនឹកមិនឃើញថាជាឈ្មោះអ្វី ឯអ្នកដែលមិនធ្លាប់ឃើញព្រះភក្ត្រព្រះរាជាវិរជ ក៏មិនមានសង្ស័យ ។

ខណៈអ្នកមើលទាំងឡាយកំពុងនឹកស្មានទៅផ្សេង ៗ នានា ព្រះរាជាវិរជ ក៏ស្ដេចយាងចូលមកក្នុងព្រះទីនាំងគំនាល់ព្រះភក្ត្រឡើងក្រហមកាលទតឃើញអ្នកប្លែកមុខបង្ហាញឡើងទៅអង្គុយលើបល្ល័ង្ករបស់ព្រះអង្គ ទ្រង់សម្គាល់ក្នុងព្រះហឫទ័យថា ខ្ញុំរាជការក្នុងព្រះសំណាក់ ព្រមគ្នាបាត់ឧប្បត្តិឡើង ជាកិច្ចសម្ងាត់ការមានជ័យជម្នះពួកក្បុរព្រះលោហិត ពុះខ្ជួលជ្រួលក្នុងព្រះវរកាយ កាលមកនឹកដល់សេចក្ដីមុខក្រាស់ ឥតខ្មាសរបស់ពួករាជបរិពារឡើងមក គួរឬមកបណ្ដោយឲ្យកញ្ជះគេឡើងទៅអង្គុយលើរាជបល្ល័ង្កសប្បាយ ជាការទុរាចារដល់ព្រះទីនាំងដ៏សក្តិសិទ្ធិរបស់ខត្តិយរាជជាបំផុត ទ្រង់រំពឹងថា សេចក្ដីបញ្ចោលលេងដូចនេះប្លែកណាស់ណា រាគង់នឹងកាត់ក្បាលអញក្នុង ១ ថ្ងៃមិនខាន ។

លុះស្ដេចយាងចូលមកជិត ទ្រង់ចាំមុខអ្នកអង្គុយលើបល្ល័ង្កនោះបានថា អ្នកនោះជាអ្នកបម្រើការរបស់ព្រះអង្គគឺអ្នកកម្សត់ ដែលព្រះអង្គទទួលគេទុកឲ្យនៅ ជាខ្ញុំល្អងធូលីព្រះបាទដោយសេចក្ដីករុណាដល់គេនោះឯង

កាលទ្រង់ជ្រាបដូចនោះ ក៏បណ្ដាលព្រះទោសហឹខ្លាំងឡើងទៀត ត្រាស់ព្រះសូរសៀងគ្រេវថា យ៉ាងម្ដេចនេះហើយ ។

គន្ទរបាល សេនាបតីម្នាក់ក្រោកឈរឡើង ក្រាបទូលថា សូមទ្រង់បន្ធូរព្រះទោសសិនព្រះករុណា អ្នកប៉ូកមុខដែលអង្គុយលើបល្ល័ង្ករបស់ព្រះអង្គនោះ មិនមែនជាទៃឆ្ងាយ គឺមហារាជយុធិស្ឋិរ គួរសរសើរថា យើងជាអ្នកមានភ័ព្វដ៏ប្រសើរដែលព្រះរាជាដ៏ជាប្រមុខនៃក្សត្រិយ៍ទាំងឡាយបានមកប្រថាប់ជាប្រធានក្នុងទីនេះ ។

ព្រះរាជាវិរាដទ្រង់ត្រាស់មិនចេញមួយស្របក់ ជីពចរដើរខ្លាំង ហើយញាប់ញ័រតឹក ៗ ឲ្យនឹកធ្ងល់ខ្វល់ក្នុងព្រះហឫទ័យ ព្រះហឫទ័យស្ទុះស្ទុះធ្លាក់ថ្លែងមួយរយមួយពាន់សា នឹងយកជាការអ្វីមិនបាន លុះទ្រង់ពឹងមួយស្របក់ធំសេចក្ដីសន្ធិះនោះក៏រលាយបាត់ទៅ ទើបទ្រង់ថ្វាយគំនាប់មហារាជយុធិស្ឋិរដោយគោរពហើយទូលថា សូមមេត្តាប្រោសព្រះរាជទានទោសព្រះករុណាចូលព្រះទានអហោសិកម្មដល់ទូលបង្គំ ដែលប្រមាថភ្លាំងភ្លាត់ទៅហើយ សូមព្រះអង្គទទួលទូលបង្គំទុកជាខ្ញុំតទៅព្រះករុណា ។

ត្រាស់ប៉ុណ្ណោះហើយ ក៏ទ្រង់ព្រះកន្សែងអាក់អួលដោយទ្រង់រឭកឡើងមកដល់កាលដែលកន្លងទៅហើយរឿងដែលបាណ្ឌវ ក្សត្រិយ៍ចូមអង្គមកនៅបម្រើព្រះអង្គយ៉ាងបាវ ទ្រង់តូចព្រះហឫទ័យជាទម្ងន់ កាលមកគិតដល់ការដែលបានប្រើប្រាស់មហារាជ ដូចបាវព្រាវទ្រង់ជ្រាបព្រះអង្គថា បានកន្លងអកុសលកម្មមួយយ៉ាងដែលគ្មានផ្លូវនឹងអច្ចយោទោសនេះ

បាន ក្រៅពាក្យស្ទាប់បន្ថែមប៉ុណ្ណោះ ។

យុធិស្ធិរ ឃើញព្រះរាជាជាទុក្ខដល់អំពើល្មើសដូចនោះ ក៏ស្ទុះក្រោកឡើងឈរមុខបល្ល័ង្ក ឱបអង្គព្រះរាជា ហើយត្រាស់ថា ខ្ញុំនឹងអរហោសិកម្មសេចក្តីប្រមាទភ្លាំងភ្លាត់ ដែលទ្រង់មិនបានធ្វើសោះ យ៉ាងដូចម្តេច ខ្ញុំវិញគួរតែសូមអភ័យ នឹងអំណរគុណបុណ្យទ្រង់ដែលមេត្តាឲ្យខ្ញុំសំណាក់ពាក់អាស្រ័យនឹងទ្រង់ឧបត្ថម្ភការពារអន្តរាយក្នុងគ្រាគ្រោះថ្នាក់នេះ ។ មិនដូចនោះទេ ព្រះករុណាបើប្រសិនជាមានហេតុល្អកើតឡើងក្នុងទីនេះសោតក៏មែនដទៃឆ្ងាយ គឺថ្ងៃសម្លាប់ដែលបានអបលោកព្រះអង្គក្នុងដំណែងជាទៅហ្វាយជីវិតជាខ្ញុំព្រះអង្គ ។

អើ អើ ចូរលើកពាក្យសំណើរនេះ ទុកអធិប្បាយក្នុងកាលដទៃចុះ ទ្រង់ជ្រាបឬទេថា យើងបានរាយកង៉ទ័ពកុរុដែលរុកកទចូលមកជាន់ដែនក្នុងគ្រាទី ២ ឲ្យបាក់បបរត់ខ្ចាយផាយទៅវិញ ក្នុងកាលទ្រង់មិននៅៗ

ទូលបង្គំទើបនឹងដឹងឥឡូវនេះឯងព្រះករុណាមិនទុកព្រះទ័យឬ ដែលនឹងឲ្យទូលបង្គំដឹងខ្លះថា ព្រះអនុជរបស់ព្រះអង្គនឹងរាជិនីទ្រៅបទី ឥឡូវនេះសំណាក់នៅឯណា ។

គេសំណាក់នៅទីនេះទាំងអស់ តែប្តូរផ្លាស់នាមយ៉ាងដទៃ ។ ដើម្បីបំបិទបំបាំងឈ្មោះដើម នេះគឺនកុលមាននាមជាគ្រន្ថិត នេះសហទេពផ្លាស់នាមជា តន្តីបាលជាអមាត្យរបស់ទ្រង់ នេះអរជុន ជានាយសារ-ថីរបស់ទ្រង់ នេភីម ផ្លាស់នាមជា ពល្លក ជាអ្នកសម្លាប់កិច្ចការខ្ញុំមាន

សេចក្ដីតូចចិត្តច្រើន ដែលទើបនឹងមកលាន់ហាក្នុងវេលានេះ ឯទ្រៅ-បទីទេវីផ្លាស់នាមជា សៃរិន្ធ្រីជាសាវឡឹកអ្នកគាល់បម្រើជិតដិតរបស់ព្រះកនីវិរាដដែលកិច្ចក វង្វេងវល់ស្រឡាញ់ទាល់តែស្លាប់ខ្លួន ព្រះកជាទ្រង់ស្ដាប់យុធិស្ឋិរថ្លែងរឿងរ៉ាវហេតុមកដល់ត្រង់នេះ ក៏មានសេចក្ដីធ្ងល់នឹងអស្ចារ្យក្នុងព្រះហឫទ័យ កាលកិរិយានៃកិច្ចកជារឿងឲ្យកើតសោកសៅក្នុងកាលដ៏កន្លងទៅហើយក៏ពិត តែវេលានេះមិនមកប៉ះពាល់ព្រះហឫទ័យដូចរឿងដែលត្រាស់ឲ្យចងដៃចងជើងទ្រៅបទីបោះក្នុងគំនរអគ្គី វេលានេះទ្រង់ឃើញថា មរណភ័យ ដែលកិច្ចកបានទទួលនោះជាទោសទណ្ឌដ៏សាល សម្រាប់លាមកដែលកិច្ចកបំណងនឹងលើកខ្លួនផ្ទឹម និងស្រីម្នាក់ដែលសក្តិសិទ្ធិជាងមាតាបង្កើត បរិសុទ្ធជាងទេពធីតាក្នុងឋានសួគ៌ ទ្រង់ឃើញទោសព្រះអង្គឯងដែលបានព្រមព្រៀងឲ្យព្រះមហេសីធ្វើការកាប់កិនសម្មានសក្តិព្រះកនិនីទ្រៅបទី អ្នកបរិសុទ្ធរកមន្ទិលគ្មានទោះបីយុធិស្ឋិរលួងលោមយកចិត្តដូចម្ដេចក្ដី ក៏មិនបាត់សោកសៅក្ដៅក្ដួលហឫទ័យ កាលមករំឭកដល់រឿងប្រមាទក្ដាំងក្ដាត់ដែលកន្លងទៅហើយក៏កើតវិប្បដិសារីសោបសល់ខ្វល់ខ្វែងចិន្ដាយុធិស្ឋិរទើបអញ្ជើញទ្រង់ ឲ្យចូលទីសៃយាសន៍ព្រោះការនិទ្រាជាឱសថ សម្រាប់រម្ងាប់សេចក្ដីទុក្ខសោកបានមួយយ៉ាងហើយត្រាស់ថា យើងឈប់និយាយហើយ បើសម្ដីរបស់យើង ដែលនិយាយចេញទៅចេះតែធ្វើឲ្យអស្សុជលរបស់ទ្រង់ ហៀរហូរដូចនេះ ម្នាលមហារាជរឿងដែលកន្លងទៅហើយគួរគប្បីដឹងថា រួចទៅហើយ មិនគួរនឹងអំពល់

ទៅរំពឹងយកមកវិញ ឲ្យតែកើតសោកស្រណោះទទេៗ សឹងរកខ្លឹមសារបន្តិចគ្មាន លោកអ្នកមានបណ្ដាសក្ដិខ្ពស់ជាងខ្ញុំជាច្រើនអ្នកបានប្រសប់កប់សេចក្ដីលំបាកលំបិន ជាងសេចក្ដីលំបាកដែលឧប្បត្តិដល់ខ្លួនខ្ញុំក្នុងគ្រានេះជាច្រើន ទ្រង់មកបន្ធូរអស្សុជលសស្រាក់ដូចនេះ ធ្វើឲ្យចិត្តខ្ញុំខ្លោចផ្សាពន់ប្រមាណជាងពាក្យប្រមាទមើលងាយ ដែលទ្រង់ធ្វើដល់ខ្ញុំដោយមិនដឹងខ្លួននោះវិញឬឈឺចាប់ជាងការធ្ងន់ឯណានិមួយ ដែលទ្រង់នឹងគប្បីបង្គាប់ឲ្យខ្ញុំធ្វើ ទ្រង់ក៏ជាប្រាជ្ញកាលណាហ្ន៎ បញ្ញារបស់ទ្រង់នឹងប្រតិបត្តិរក្សាព្រះអង្គទ្រង់ បើទ្រង់រម្ងាប់ព្រះហឫទ័យក្នុងរឿងនោះសម្រាប់ព្រះអង្គទ្រង់មិនបាន ក៏ចូលរម្ងាប់ដើម្បីឃើញដល់ខ្ញុំចុះ ។

វេលានេះព្រះរាជាវិរាដទ្រង់រម្ងាប់ត្រឡប់ព្រះហឫទ័យបាន ហើយដោយទ្រង់ចិន្តាថា រឿងទុក្ខទោមនស្សនេះ មិនមែនឲ្យក្ដៅក្រហាយតែខ្លួនឯងទេ ជាផ្លូវឲ្យក្ដៅក្រហាយដល់រាជាធិរាជ របស់ទ្រង់ផង ដោយប្រការដូចនេះ ទើបទ្រង់ព្យាយាមយ៉ាងពេញសតិបញ្ញា ដើម្បីហាមឃាត់អស្សុជលធ្លាក់ ។

តាំងពីយុធិស្ឋិរ ត្រូវនិរទេសទៅដើរព្រៃ ការទារុណកម្មលាមកជាច្រើនយ៉ាងដែលកើតឡើងក្នុងវដ្ដសីមាឥន្ទ្របថ អយុត្តិធម៌និងការគ្រប់គ្រងមិនត្រូវទំនៀមបានកើតឡើងទូទៅទាំងព្រះរាជអាណាចក្រ ព្រះរាជវាំង ឥន្ទ្របថគ្រាមួយនោះល្អចិញ្ចែងរកទីប្រៀបគ្មាន ឥឡូវនេះក្លាយទៅជាសំបុកប្រចៀវនឹងព្រាបទាំងឡាយ មានចោរលួចប្លន់បៀតបៀនអ្នក

ស្រុកឲ្យបានសេចក្ដីក្ដៅក្រហាយជាញឹកញយ  របៀបការគ្រប់គ្រងបានផ្លាស់ប្ដូរខុសរូបដើមជាច្រើន  ព្រោះប្រទេសនិមួយៗ  ដែលទឹងចម្រើនរុងរឿងនឹងពោលសារុបរួមតែក្នុង ១ ម៉ាត់ថា  អំណាចជាធំ  នេះជារបៀបអ្នកធ្វើការគ្រប់គ្រងប្រទេស  នឹងអ្នកនៅក្រោមសេចក្ដីគ្រប់គ្រងប្រទេសឥន្ទ្រូបថដែលធ្លាប់សុខសាន្តត្រាណនិពសក័យមក អំពីដើមត្រឡប់ទៅជាចលាចលស្អុះស្អាប់និគររាស្ត្រទាំងឡាយ  ចង់តែឲ្យយុធិស្ឋិរត្រឡប់ទៅព្រះនគរវិញ  គេនាំគ្នារាប់ខែកប់ឆ្នាំ  ចាំមើលផ្លូវបិយមហារាជរបស់គេដោយសេចក្ដីរំជួលចិត្ត  ពណិមានរឿងបាណ្ឌវក្សត្រិយ៍ស្ដេចទៅនៅក្នុងសំណាក់វិរាដបានល្បីខ្ទរទៅក្នុងនានាប្រទេស  ពួកក្សត្រិយ៍សាមន្តរាជដែលនៅក្នុងសេចក្ដីគ្រប់គ្រងរបស់ក្សត្រិយ៍មហាសាលយុធិស្ឋិរ  បាននាំគ្នាម្នីម្នាទៅឋានក្រុង ដើម្បីសម្ដែងសេចក្ដីគោរព  នឹងថ្វាយសេចក្ដីដល់បរមក្សត្រិយ៍ដ៏ជាចៅហ្វាយនាយរបស់គេ  អ្នកខ្លះគោងដើរដើងទៅ  មានសេចក្ដីនឿយលំបាកដោយមាគ៌ាដ៏ឆ្ងាយ  ដើម្បីឃើញព្រះភក្ត្រមហារាជារបស់គេម្ដងទៀត  អ្នកខ្លះក៏នឹកប្ដុស្សាព្រះចៅវិរាដ  ដែលឲ្យយុធិស្ឋិរសំណាក់អាស្រ័យនៅក្នុងម្លប់សំយ៉ាប ។

តែយុធិស្ឋិរនឹងត្រឡប់ទៅនគរវិញ ដោយសុវត្ថិភាពមិនបាន ដោយទ្រង់ជ្រាបថា  នឹងគោងចាំងគ្រប់ដំហាន  ដែលឈានត្រឡប់ទៅវិញ  ទើបទ្រង់ប្រឹក្សានឹងព្រះរាជាវិរាដរាជសម្ពន្ធមិត្រក្នុងរឿងនេះ  ដើម្បីកំណត់គ្រោងការសង្គ្រាម  ដែលនឹងលើកទៅរាយយកដែនដីរបស់ព្រះអង្គដែល

បណ្ដាលឲ្យយើងត្រូវនិរទេសនោះសព្វគ្រប់ហើយ ពង្សាវតារដ៏ល្បីនាម ក្នុងជីវិតរបស់ខ្ញុំអាចនឹងសារុបបានក្នុងពាក្យមួយម៉ាត់ថា ការក្នាល់ប៉ុណ្ណោះឯង ខ្ញុំយកអាណាចក្រនិងឥស្សរភាពទៅក្នាល់នឹងគេ ចាញ់គេពល់ក្ដារមិនថាក្ដារណា តែបង់ចុះក៏បាត់ទៅ មិនបង់តែមកុដរបស់ខ្ញុំ បង់ទាំងខ្លួនធ្លាក់ទៅជាខ្ញុំគេផង ព្រមទាំងទ្រព្យទឹកដីជាបណ្ដូលចិត្ត តែដែលបង់នាងទៅ ខ្ញុំមិនសូវទោមនស្សតូចចិត្តស្មើនឹងសេចក្ដីអាម៉ាស់មុខ ត្រង់ដែលទុហសាសន ចាប់សម្រាតនាងកណ្ដាលទីប្រជុំជន គ្រានោះចិត្តខ្ញុំស្ទុតសង្វេគស្មើរទ្រាំពុំបាន តែបានព្រះករុណាធិគុណព្រះអយ្យកោ ភីស្មៈ ដែលទ្រង់បានពោលជាផ្លូវប្រឹក្សាថា ការដែលធ្វើទោសទណ្ឌកម្ម ដល់យើង សុំឲ្យធ្វើជាការនិរទេសចេញចាកនិវេសនស្ថាន រហូតវេលា ១៣ ឆ្នាំ ជាកំណត់ យើងក៏ព្រមទទួលទណ្ឌកម្មនោះ ដោយតុណ្ហីភាព ទោះបីទណ្ឌកម្មនោះតឹងរឹងខ្លោះក្ដីតថា យើងបានទទួលសោយទរមានកម្មលំបាកលំបិនដល់ខ្នាត រហូតកាលកំណត់និរទេសក្នុងវេង់នោះពេញទៅដោយសេចក្ដីទុក្ខព្រមទាំងអន្តការ ទើបនឹងបានឃើញពន្លឺដ៏រុងរឿង ពោលគឺសេចក្ដីមេត្តារបស់ទ្រង់ ដែលទ្រង់ទាក់ទទួលឲ្យទៅជាសុខក្នុងអំណាចអារក្ខាក្នុងកជសំណាក់នោះ ឥឡូវនេះយើងខ្ញុំបានទទួលនិរទេសទណ្ឌកម្មនោះដោយសុចរិតគ្រប់ធុនបានតាមកំណត់ហើយ បានប្រតិបត្តិយ៉ាងតឹងរឹងតាមខសន្យាដែលចងរឹតខ្ញុំនោះគ្រប់ប្រការ វេលានេះខ្ញុំមានសេចក្ដីធូរ

ស្រួលក្នុងចិត្តគិតនឹងត្រឡប់ទៅស្រុកទេសរបស់ខ្ញុំវិញ នឹងត្រាំដើរទៅសំចតឯណោះបន្តិចឯណេះបន្តិចដូចចចក រហូតនិរន្តរកាលទៅមិនបាន ។

ព្រះពជាវិរាជតបថា ទូលបង្គំជឿជាប្រាកដថា នឹងបានព្រះនគរមកវិញ ដោយមិនតោងធ្វើសង្គ្រាមនោះជាមិនបាន ក្រឹបរបស់យើងតែមួយយ៉ាងប៉ុណ្ណោះ អាចនឹងចាត់ការវិវាទឲ្យស្ងប់ទៅបាន ឬឲ្យដាច់ស្រេច ព្រោះថាអ្វីដែលបង់ទៅដោយអយុត្តិធម៌នោះ កម្រនឹងត្រឡប់បានមកវិញដោយប្រតិភាព ។

ក្នុងខណៈនេះទ្រោបទីក៏យល់ឃើញផង នាងជាស្រីក៏មែន តែនាងជាក្សត្រិយ៍ជាតិអ្នកចម្បាំង ហើយជាមហេសីក្សត្រិយ៍ នាងទើបមានសវនិយថា ការដែលព្យាយាមសំរួបសំរួមបងប្អូន ដែលទាក់ទងខ្សែគំនិតគ្នាគ្រានេះស្មើដូចយល់ស្រប ការទុច្ចរិតបង់ពាក្យសត្រូវបានទទួលផ្ទាន់តែ ១ យ៉ាង គឺបរណៈទុរយោធន៍ យកប្រៀបទ្រង់យ៉ាងម្តេចខ្លះ គេផ្ទាសបញ្ឆោតទ្រង់ឲ្យចូលទៅក្នុងអគ្គប់យ៉ាងម្តេច គេក្លែងតែងរៀបហារធ្វើជាលេងល្បែងក្លាល់យ៉ាងញាតិយ៉ាងមិត្រ តែកលគិតយកពជអាណាចក្ររបស់ទ្រង់ទៅ បណ្តេញទ្រង់ឲ្យចុះចាកផ្ទះសម្បែង នឹងចាកប្រយូរវង្សរបស់ទ្រង់យ៉ាងម្តេច ព្រះហឫទ័យរបស់ទ្រង់គង់ជាពក់មិនចាក់ចុះទៅក្នុងឧបាយកលនោះ ទើបប្រមាទភ្លាំងភ្លាត់ទៅព្រៀវដល់ម្ល៉េះ ឲ្យការសង្គ្រាម ១ យ៉ាងចេញមុខនេះវិញវិនិច្ឆ័យ ទើបនឹងដឹងថា ខាងណាខុសធម៌ខាងណាត្រូវធម៌ ។

ព្រះយុធិស្ធិរ តបដោយគិតទុកមកហើយថា បងចង់លចិត្តនាងមើល ក្នុងរឿងនេះ តើជាយន់យលដូចម្តេច បងនឹងបញ្ជូនទូត ជាប្រញាប់ឲ្យនាំ ពតិមានទៅដល់រាជបរិពារ និងព្រះរាជាដ៏ជាប្រធានក្នុងប្រទេសនោះ ។ បញ្ជូនរាជទូតមួយប៉ែកទៅកាន់រាជសំណាក់ ស្រីក្ឫស្ណ(១) ព្រះរាជាប្រទេស ទ្វារក ឲ្យយកចិត្តឈឺឆ្អាលខាងបងក្នុងការសង្គ្រាមគ្រានេះ អរជុនទនេះ ឯងជាទូតរបស់បង ។

ព្រឹកឡើងថ្ងៃតអំពីនោះ អរជុនក៏អញ្ជើញរាជសាសន៍ទៅកាន់ក្រុងទ្វា-រកជាព្រះនគររបស់ព្រះក្ឫស្ណ (ក្រិស្ណ) សឹងតាំងនៅមាត់ទន្លេខាងលិចរយៈ ផ្លូវឆ្ងាយ ក្នុងដែនឥឡូវនេះហៅថាគូជរត អរជុនធ្លាប់ទៅមកកាន់រាជ សំណាក់ក្ឫស្ណឆាំដំបូង ។ ក្នុងរវាង ១២ ឆ្នាំ ដែលត្រូវនិរទេសនោះ រាជ កុមារទាំងពីរនេះជាសម្ពន្ធមិត្រ ស្និទ្ធស្នាលគ្នាច្រើនទាំងជាប់ជាព្រះញាតិ នឹងគ្នាផង ក្នុងឱកាសដែលទៅគ្រានោះ អរជុនបានឃើញក្សត្រិយ៍ ១ អង្គ តែងកាយរៀបរយដើរចូលទៅក្នុងព្រះរាជវាំងទ្វារក ចូលមុនអរជុន មិនប៉ុន្មានជំហាន មើលទៅភាពក្សត្រិយ៍នោះ ឃើញថាជាអ្នកដើរផ្លូវ ឆ្ងាយដូចគ្នា ហើយមើលទៅឃើញថា មានធុរៈប្រញាប់ដូចគ្នាអ្នកយាម ទ្វារអនុញ្ញាតឲ្យចូលទៅដោយស្រួល មើលទៅកិរិយាដូចជាព្រះរាជមិត្រ ឬ ព្រះញាតិនឹងព្រះរាជក្ឫស្ណ អរជុននឹកឆ្ងល់ថា ជាអ្នកណាហ្ន៎តែគ្មានវេលា

១ – ក្ឫស្ណ សព្ទនេះ ជាភាសាសំស្ក្រឹត ភាសាមគធជា (កណ្ហ) ប្រែថា ស្ពោទ្មៅ ។ នេះ ព្រះ នារាយណ៍បែងភាគឲ្យមកកើត ដូចមានប្រាកដក្នុងសេចក្តីរាពណ៍រឿងអង្គ ដែលយើងខ្ញុំតែង ក្នុងឆ្នាំ ១៩២៦ ។

នឹងសាកសួរឲ្យអស់សង្ស័យ ក្នុងរឿងដ៏ឥតប្រយោជន៍ ព្រោះទ្រង់មកជាការពដការស្មេសកន់ព្រះហឫទ័យខ្វល់ទៅតែក្នុងរឿងរាជការ ។

កាលស្តេចចូលទៅដល់ទ្វារវាំង នាយទ្វារបាល ក៏អនុញ្ញាតឲ្យចូលទៅដោយស្រួលដូចគ្នា ដោយមិនបាច់ចាំធ្វើរបៀបយ៉ាងម្តេច តែវេលានោះបានទ្រង់ជ្រាបថាក្សត្រកំពុងផ្ទុំសម្រាន្តនិទ្រារម្មណ៍ក្នុងវេលារសៀលទ្រង់ ក៏ចូលទៅក្នុងបន្ទប់ក្រឡាបន្ទំ តែមិនមែនជាប្រុសទៅជាស់ចូលទៅរង់ចាំក្នុងទីនោះតែម្តង ដើម្បីកុំឲ្យខាតវេលា កាលស្តេចតើនឡើងនឹងបានទូលស្នើតាមការខណៈដែលអវេជ្ជនឈានចូលទៅក្នុងបន្ទប់ក្រឡាបន្ទំ ព្រះរាជាមានភៀវម្នាក់ទៀតជ្រៀតដើរចូលទៅផង ដើរស្រាវដើងទៅមុខអវេជ្ជនពីរបីជំហាន រាជកុមារអគ្គនោះក៏យកកំ ចូលទៅឈរខាងដើមព្រះខែនបន្ទំក្បែរព្រះសិរ អវេជ្ជនចូលទៅឈរខាងចុងព្រះខែនការ ដែលមានមនុស្សពព្រួសពព្រាសធ្វើឲ្យព្រះរាជាតើនបន្ទំ កាលបើកព្រះនេត្រឡើងក៏ឃើញអវេជ្ជនដែលនៅចុងព្រះបាទមុន ដោយសេចក្តីបីតិព្រាព្រួច ដែលបានជួបព្រះរាជសម្ពន្ធមិត្រដ៏ស្និទ្ធស្នាល ក៏ត្រាស់សួរដោយរួសរាន់ថា អវេជ្ជនទ្រង់មកពីអង្កាល យើងមានសេចក្តីសោមនស្សណាស់ ដែលបានឃើញមុខបិយមិត្រ ។

ទូលបង្គំទើបនឹងមកអម្បាញ់មិញ ។

ទូលបង្គំមកមុននេះជាសម្តីអកម្នាក់និយាយកាត់ឡើង ពាក់កណ្តាលភៀវដែលមកកេម្នាងនោះ គឺទុរយោធន៍ កាលក្រិស្ណ ប្រែព្រះភក្ត្រទៅ

ខាងអ្នកនិយាយក្រោយនេះ ឃើញក្រិស្ណ ឈរខាងជើងព្រះទែនថ្វាយគំនាប់ ក៏ត្រាស់ថា យូរហើយណា ទើបនឹងមកជួបគ្នាក្នុងថ្ងៃនេះសិទ្ធិជោគស្មោកល្អនាំទ្រង់ឲ្យមកដល់ទីនេះ ។

ទុរយោធន៍ចង់បានក្រិស្ណជាសម្ពន្ធមិត្រ ដោយសិទ្ធិភាពជាអ្នកមកដល់មុន (ព្រោះព្រះវេណីក្សត្រិយ៍ឥណ្ឌូបុរាណ ថាបើកើតហេតុទាស់ទែងគ្នាឡើង នឹងសុំឲ្យជួយរាំងបរប័ក្ស គេច្រើនតែទទួលជួយខាងអ្នកមកដល់មុន) មិនបានប្រាស្រ័យបដិសន្ធារឲ្យយឺតយូរពោលតែកំប៉ុក ៗ ថាទូលបង្គំសូមឲ្យព្រះអង្គមានភាគជំនួយក្នុងការសង្គ្រាម ដែលនឹងមានមកសូមព្រះអង្គជាប័ក្សខាងទូលបង្គំ ។

អជ៌ុនមិនបានស្រែកសុំសេចក្តីជំនួយកប្រៀបមុន ក្រោយដូចនោះអង្គុយតែស្ងៀមក្រិស្ណដញ្ជឹងមួយស្របក់ក៏ត្រាស់ថា ខ្ញុំឥតមានរើសទាល់ទេ ក្នុងការដែលនឹងប្រគល់កម្លាំងយោធារបស់ខ្ញុំ ដើម្បីជាប្រយោជន៍ដល់ទ្រង់ឯណានីមួយឬទាំងសងខាង តែខ្ញុំសុំនិយាយបំភ្លឺត្រង់នេះសិនតាមសេចក្តីយល់ឃើញរបស់ខ្ញុំ អ្នកទាំងពីរមានភាគស្មើគ្នា ដើម្បីនឹងរក្សាជញ្ជីងត្រាជូវឲ្យទៀតត្រង់ រាំងសេចក្តីសម្ពន្ធមិត្រសម្រាប់ខ្លួន នឹងសម្រាប់ប្រទេស ខ្ញុំសុំប្រគល់កងទ័ពដើងគោកនិងកម្លាំងទ្រព្យទាំងមូលក្នុងអាណាចក្រឲ្យម្ខាងតែម្ខាងទៀត ខ្ញុំចង់ប្រគល់ខ្លួនខ្ញុំ ឲ្យដោយមិនបានកាន់អាវុធ ឬពាក់ក្រិស្ណគ្រឿងការពារខ្លួន ឥឡូវនេះសូមឲ្យទ្រង់ទាំងសងខាងរើសយកតាមគាប់ចិត្តចុះ ។

ទុរយោធន៍ទូលដោយរួសរាន់ថា ទូលបង្គំសុំទទួលយកខាងកងទ័ពគោក និងធនទ្រព្យទាំងពួងជារបស់ខាងទូលបង្គំ ។

អរជុនទូលថា ទូលបង្គំមានសេចក្តីអំណរលន់ ដែលបានក្រិស្ណមកជាពួកខាងទូលបង្គំ ទូលបង្គំរាប់យកតម្លៃមិត្តភាពយ៉ាងក្រិស្ណ ខ្ពស់ជាងកម្លាំងពលទាហានរបស់ព្រះអង្គ ។

គ្រានោះកងទ័ពគោករបស់ព្រះចៅក្រិស្ណ ក៏ចាត់ចែងលើកទៅក្រុងហស្តិនបុរ ដោយរួសរាន់ ទុរយោធន៍ជាអ្នកនាំទ័ពទៅឯង ក្នុងវេលាជាមួយគ្នានោះ ក្រិស្ណក៏ស្តេចតាមអរជុនទៅឯក្រុងវិរាដស្តេចទៅគ្រានេះគ្មានកាន់អាវុធគ្មានរាជបុរសតាមស្តេចទៅផងទេ កាលក្សត្រិយ៍ទាំងពីរទៅដល់រាជសំណាក់ ព្រះចៅវិរាដហើយមានការប្រជុំប្រឹក្សាសើរឿងបាណ្ឌវ ក្សត្រិយ៍ក្រិស្ណប្រថាប់ជាប្រធានក្នុងទីប្រជុំនោះ ទ្រង់ព្យាយាមតែនឹងបំបាត់មិនឲ្យកើតសង្គ្រាមកាប់សម្លាប់គ្នា វេលានោះទ្រង់ក្រោកឈរឡើងពោលសុន្ទរកថា សំរួបសំរួល ដើម្បីឲ្យស្ងប់សឹក ដើម្បីសេចក្តីជាមិត្រ ក្នុងទីបំផុតបានព្រមព្រៀងគ្នាតាមពាក្យណែនាំរបស់ក្រិស្ណឲ្យបញ្ជូនទូតទៅគាល់រាជាធតរាស្ត្រព្រះញាតិជាន់អ្នកធំ ដើម្បីធ្វើការសាមគ្គីសន្តានិងគោរព ។

(នៅមានត)